**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:៨១
ចុះថ្ងៃទី១៧ ខែកម្ភៈ ឆ្នាំ២០០៤
**<u>សាលដីកា</u>**
លេខ:០២
ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ................ ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក .................. ជាចៅក្រមរបាយការណ៍
៥-លោក ................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក ..................

**<u>តំណាងមហាអយ្យការ</u>**

-លោកបណ្ឌិត .............. ជាព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៨៥៥ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះ ឆក(ជាចុងបណ្ដឹងសាទុក្ខ) ផ្ទេរសិទ្ធិឱ្យឈ្មោះ កយ ភេទស្រី អាយុ៤៤ឆ្នាំ មុខរបរនៅផ្ទះ ទីលំនៅភូមិសុវណ្ណសាគរ ឃុំកំពង់កណ្ដាល ស្រុកកំពង់បាយ ខេត្តកំពត ។

មានលោក ...............ជាមេធាវី និងជាតំណាង ។

ចុងចម្លើយឈ្មោះ មបធ(ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរ មន្ត្រីសេដ្ឋកិច្ចសាលាខេត្តតាកែវ ទីលំនៅភូមិស្តោរ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ។

**<u>កម្មវត្ថុបណ្ដឹង:</u>** ប្ដឹងទាមទារដី១៩ម x ៣០ម និងផ្ទះ ៤ម x ៨ម

បានឃើញបណ្ដឹងសាទុក្ខលេខ៣១៨ ចុះថ្ងៃទី២០ខែសីហាឆ្នាំ២០០៣ របស់ឈ្មោះមបធប្ដឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៨១ចុះថ្ងៃទី១៧ ខែកុម្ភៈឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១០-០៦-២០០១ របស់ដើមចោទឈ្មោះឆកថាខ្លួនប្ដឹងទាមទារដីទំហំ១៩ម x៣០ម រួមទាំងផ្ទះទំហំ៤មx៨ម ដោយអាងហេតុថា ក្រោយពេលកូនស្រី ខ្លួនឈ្មោះកែវ ថាយ រៀបអាពាហ៍ពិពាហ៍រួចហើយ ពុំមានកន្លែងស្នាក់នៅ ខ្លួនក៏ឱ្យកូនរស់នៅលើផ្ទះ និងដីនេះរួមជាមួយខ្លួនដែរ ។ កូនឈ្មោះកែវ ថាយ និងប្ដីឈ្មោះមបធរួមរស់ជាមួយគ្នា បង្កើតបានកូន០២នាក់ ។ ក្រោយមកកូនប្រសារឈ្មោះមបធចេះតែរករឿងបង្កទំនាស់ជាមួយប្រពន្ធ និងខ្លួនជាញឹកញាប់ បានចុះចោលផ្ទះទៅមានស្រីផ្សេងទៀត ពុំគិតគូរប្រពន្ធ កូនឡើយ រហូតដល់កូនស្រីខ្លួនធ្លាក់ខ្លួនឈឺ ក៏ឈ្មោះមបធពុំបានគិតគូរថែទាំប្រពន្ធដែរ។ លុះដល់ថ្ងៃទី០៨-០៦-២០០១ ដោយសភាពជំងឺមានលក្ខណៈធ្ងន់ធ្ងរពុំអាចព្យាបាលបានកូនស្រីខ្លួនក៏បានទទួលមរណភាព ហើយបន្សល់ទុកកូនកំព្រាទាំងពីរនាក់ ។ ក្នុងរឿងនេះ ខ្លួនប្ដឹងទាមទារដី និងផ្ទះនេះវិញ ព្រោះខ្លាចថ្ងៃក្រោយឈ្មោះមបធយកស្រីផ្សេងមករស់នៅលើផ្ទះ និងដីនេះ ហើយទាមទារទុកជាកម្មសិទ្ធិរបស់ពួកគេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ២៥(ខ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី១០-០៦-២០០១ របស់ដើមចោទឈ្មោះឆកទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៨-១០-២០០១ របស់ដើមចោទឈ្មោះ ឆកដែលបានផ្ទេរទៅឱ្យតំណាងឈ្មោះកយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ដីទំហំ៦០៣ម$^{២}$ មានព្រំប្រទល់ខាងជើងទល់ឈ្មោះតាន់ ឆេងហួយ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ឈ្មោះឆក ខាងលិចទល់ឈ្មោះកុយ ជិន ស្ថិតនៅភូមិស្មោរ ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ និងផ្ទះដែលសង់លើដីទំនាស់ ត្រូវប្រគល់ឱ្យទៅដើមចោទឈ្មោះឆកតំណាងដោយឈ្មោះកយ ជាកម្មសិទ្ធិករតាមច្បាប់ តាមបញ្ញត្តិមាត្រាទី១៣៨ និង ១៣៩ នៃច្បាប់ភូមិបាល ។

៤-បង្គាប់ឱ្យឈ្មោះឆោម កង(ដើមចោទ) តំណាងដោយឈ្មោះកយ ចេញប្រាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ឱ្យទៅឈ្មោះមបធ(ចុងចម្លើយ) ជាប្រាក់ដែលចុងចម្លើយបានរួមចំណែកក្នុងការសាងសង់ផ្ទះ ។

៥-បង្គាប់ឱ្យចុងចម្លើយឈ្មោះមបធបង់ប្រាក់ប្រដាប់ក្ដីគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងចំណាយលើអ្នកប្រគល់ដីកាកោះចំនួន៥០០០៛ សរុប ៧០០០ ៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧០០០៛ ដែលដើមចោទ បានបង់ទុករួច ។

**កាលបើផុតកំណត់ឧទ្ធរណ៍ :**

-បង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួន៧០០០៛ ទៅដើមចោទវិញ ។

-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ពន្ធសមាមាត្រចំនួន១%លើតម្លៃដី និងផ្ទះទំនាស់ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន២០% ។

សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីទុកសិទ្ធិឱ្យប្តឹង ឧទ្ធរណ៍កីណត់២ខែគិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៧៩ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះកយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៥(ខ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចទី៤ នៃសេចក្តីសម្រេចនៃសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះមបធប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៥(ខ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តតាកែវ ត្រង់ចំណុចនៃសេចក្តីសម្រេចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៥-០៨-២០០២ របស់ឈ្មោះមបធទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩-០៩-២០០២ របស់ឈ្មោះកយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៥(ខ) ចុះថ្ងៃទី១៦-០៧-២០០២ របស់តុលាការខេត្តតាកែវ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥០០០៛ និងលើអាជ្ញាធរតុលាករចំនួន៥០០០៛ ។

៥-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣១៨ចុះថ្ងៃទី២០ខែសីហាឆ្នាំ២០០៣ របស់ឈ្មោះមបធប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧-០៦-២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និងសម្រេច ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក..............ជាមេធាវីតំណាង និងការពារឱ្យដើមចោទបាន លើកឡើងថា ដីទំនាស់ទំហំ៦០៣ម$^{២}$ ជាទ្រព្យដើមរបស់ដើមចោទ ។ ធកបានអនុញ្ញាតឱ្យប្តីប្រពន្ធរស់នៅ លើដីនេះ ហើយគាត់ក៏បានរស់នៅលើដីនេះដែរ ។ សាក្សីដែលជាម្ចាស់ដីបានឆ្លើយហើយថា ដីនេះជាដី ធកទិញពីគាត់ ។

**សំណូមពរ :** សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៣១៨ ចុះថ្ងៃទី២០ខែសីហាឆ្នាំ២០០៣ របស់ឈ្មោះមបធធ្វើ ឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការ ចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដី និងផ្ទះទំនាស់ គឺជាទ្រព្យសម្បត្តិ របស់ដើម ចោទបានទិញ និងសង់ផ្ទះដោយផ្ទាល់ ហើយបានប្រគល់ឱ្យកូនស្រីឈ្មោះ កែវ ថាយ និងប្តីស្នាក់អាស្រ័យ នៅក្រោយពេលកូនរៀបអាពាហ៍ពិពាហ៍ ដូចមានចម្លើយសាក្សីឈ្មោះគឹម ដែន ស៊ីម ជា ដែលបានឆ្លើយ ប្រហាក់ប្រហែលគ្នាថា ដីទំនាស់ជាដីដែលដើមចោទត្រូវជាម្តាយនាងកែវ ថាយ បានទិញពីឈ្មោះស៊ីម ជា តាំងពីមុននាងកែវ ថាយ រៀបអាពាហ៍ពិពាហ៍មកម្ល៉េះ រីឯផ្ទះលើ ដីក៏ឈ្មោះធកជាអ្នកចេញប្រាក់ធ្វើដែរ នាងកែវ ថាយ និងប្តីមានសិទ្ធិត្រឹមតែស្នាក់អាស្រ័យ នៅប៉ុណ្ណោះ ។

- យល់ឃើញថា ការបំភ្លឺរបស់ប្រធានការិយាល័យដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុក តាមលិខិតលេខ១៣១/១២ ចុះថ្ងៃទី១៩-០៦-២០០២ បញ្ជាក់ថាៈនៅក្នុងអំឡុងឆ្នាំ២០០២ឈ្មោះមបធ

បានសុំខ្ចីពាក្យសុំកាន់កាប់ដីពីការិយាល័យភូមិបាលស្រុក ទៅថតចម្លងទុកមើល ពេលយកមកវិញ មានថែមឈ្មោះមបធនិងស្នាមមេដៃទៀតផង ។

- យល់ឃើញថា ដី និងផ្ទះទំនាស់ជាទ្រព្យសម្បត្តិដើមរបស់ឈ្មោះកែវ ថាយ ឈ្មោះមបធគ្រាន់តែមានសិទ្ធិស្នាក់អាស្រ័យនៅលើផ្ទះនេះតែប៉ុណ្ណោះ សិទ្ធិស្នាក់អាស្រ័យនៅនេះ ត្រូវអស់សុពលភាពដោយចំណងអាពាហ៍ពិពាហ៍ត្រូវរលត់តាមមរណភាពនៃឈ្មោះកែវ ថាយ។ ដូច្នេះផ្ទះ និងដីនេះត្រូវធ្លាក់មកលើទាយាទកូនទាំងពីរ ។

- យល់ឃើញថា លោកមបធបានទទួលលិខិតបង្គាប់ឱ្យធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានធ្វើសារណាតាមការកំណត់ទេ ហើយក៏ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខ ប៉ុន្តែចាត់ទុកជា ចំពោះមុខ ។

- យល់ឃើញថា ដើមចោទពុំបានមកចូលរួមសវនាការនេះទេ ប៉ុន្តែលោកមេធាវីរបស់ ដើមចោទបានមកចូលរួមហើយ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៥៩(ច)ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៣១៨ ចុះថ្ងៃទី២០ខែសីហា ឆ្នាំ២០០៣ របស់ឈ្មោះមបធទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៥៩(ច) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែលដើមចោទ បានបង់គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

បង្គាប់ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តតាកែវ ។

៤-សាលដីកានេះ ប្រកាសនាសវនាករជាសាធារណៈនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០០៦។